សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញ
សមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
**១៨ ធ្នូ ២០១៥**

- សូមគោរព **លោក សោម សារ៉ូ** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប
- សូមគោរព **លោក ឈើយ ចាន់ណា** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ
- សូមគោរព **លោក Patrick Seger** នាយកប្រចាំប្រទេសនៃអង្គការSamaritan’s Purse International Relief
- សូមគោរព អស់លោក លោកស្រី!

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខានៅថ្ងៃនេះ លើកិច្ចសន្យាផ្តល់ជំនួយចំនួនបីសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ ដែលគម្រោងទីមួយ គឺគម្រោងសាងសង់អគារសិក្សាមួយខ្នងនៅអនុវិទ្យាល័យកែវព័ណ៌ ស្រុកពួក ខេត្តសៀមរាប គម្រោងទីពីរគឺ គម្រោងសាងសង់អគារសិក្សាមួយខ្នងនៅអនុវិទ្យាល័យឃីឡិក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ និងគម្រោងទីបីគឺ គម្រោងសាងសង់អគារសិក្សាពីរខ្នងនៅសាលាបឋមសិក្សាខ្លែងពណ៌ និងសាលាបឋមសិក្សាតាដុល ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

គម្រោងដែលបានចុះហត្ថលេខានៅថ្ងៃនេះ មានគោលបំណងដើម្បីកែលម្អបរិស្ថានអប់រំសម្រាប់សិស្សានុសិស្ស និងគ្រូបង្រៀននៅតាមតំបន់ទីតាំងគម្រោងនិមួយៗ។ ខ្ញុំជឿជាក់ថា ការធ្វើអោយប្រសើរឡើងនូវវិស័យអប់រំ គឺជាគន្លឹះមួយសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជានាពេលអនាគត។ វិស័យអប់រំ គឺជាវិស័យអាទិភាពមួយនៃបណ្តាវិស័យអាទិភាពនានារបស់រាជរដ្ឋាភិបាលកម្ពុជា។ ជាក់ស្តែង ជប៉ុនបានគាំទ្រយ៉ាងពេញទំហឹងដល់វិស័យអប់រំនៅកម្ពុជាជាងពីរទសវត្សរ៍កន្លងមកហើយ តាមរយៈការសាងសង់អគារសិក្សា និងការផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្រៀនជាច្រើន។

គម្រោងជំនួយទីមួយ ដែលមានថវិកាចំនួន៥២,៤០០ដុល្លារអាមេរិក ត្រូវបានផ្តល់ជូនដល់មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប សម្រាប់ការសាងសង់អគារសិក្សាមួយខ្នង រួមជាមួយនឹងការបំពាក់សំភារៈសិក្សាដែលចាំបាច់ ព្រមទាំងបង្គន់អនាម័យ នៅអនុវិទ្យាល័យកែវព័ណ៌។ គម្រោងនេះ គឺជាគម្រោងទី៣នៃគម្រោងគូសាណូណិផ្នែកអប់រំ ដែលបានផ្តល់ជូនដល់ខេត្តសៀមរាប។ ជាមួយនឹងគម្រោងនេះ សិស្សានុសិស្សនៃអនុវិទ្យា

ល័យប្រមាណជាង២៣០នាក់ នឹងអាចសិក្សានៅក្នុងថ្នាក់រៀននេះ ដោយមានចំនួនសិស្សសមស្របតាមនិយាមគរុកោសល្យក្នុងមួយថ្នាក់ៗ ជាមួយនឹងបរិស្ថានអប់រំប្រកបដោយផាសុខភាព ។

គម្រោងជំនួយទីពីរ ដែលមានថវិកាចំនួន៦៧,៦៣១ដុល្លារអាមេរិក ត្រូវបានផ្តល់ជូនដល់មន្ទីរអប់រំ យុវជននិងកីឡាខេត្តបន្ទាយមានជ័យ សម្រាប់ការសាងសង់អគារសិក្សាមួយខ្នង និងបង្គន់អនាម័យ នៅអនុវិទ្យាល័យឃីឡិក ក្នុងខេត្តបន្ទាយមានជ័យ។ គម្រោងនេះ គឺដើម្បីផ្តល់អត្ថប្រយោជន៍ជូនដល់សិស្សានុសិស្សប្រមាណជា២៨០នាក់ ដែលសិស្សានុសិស្សទាំងអស់នេះ នឹងមានថ្នាក់រៀននៅក្នុងបរិវេណសាលារៀនរបស់ពួកគេ។

គម្រោងជំនួយទីបី ដែលមានថវិកាចំនួន៨៩,១០៤ដុល្លារអាមេរិក ត្រូវបានផ្តល់ជូនដល់អង្គការ Samaritan’s Purse International Relief សម្រាប់សាងសង់អគារសិក្សាពីរខ្នង នៅសាលាបឋមសិក្សាខ្លែងពណ៌ និងសាលាបឋមសិក្សាតាដុល ខេត្តបន្ទាយមានជ័យ។ អគារទាំងពីរខ្នងនេះ គឺស្ថិតនៅតំបន់ដាច់ស្រយាល ហើយសិស្សានុសិស្សទាំងអស់ត្រូវបង្ខំចិត្តរៀននៅក្នុងអគារសិក្សាធ្វើពីឈើដែលមានសភាពចាស់ទ្រុឌទ្រោម។ បន្ទាប់ពីគម្រោងនេះត្រូវបានបញ្ចប់ សិស្សានុសិស្សប្រមាណជា ២៨០នាក់ នឹងអាចសិក្សានៅក្នុងថ្នាក់រៀនថ្មីប្រកបដោយសុវត្ថិភាព និងផាសុខភាពជាងមុនមិនខាន។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អគារសិក្សាទាំងបួនខ្នង ដែលត្រូវបានសាងសង់ដោយគម្រោងទាំងនេះ នឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវអោយបានយូរអង្វែង ដើម្បីអោយសិស្សានុសិស្ស និងលោកគ្រូ-អ្នកគ្រូកាន់តែច្រើន អាចប្រើប្រាស់ និងទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនេះតាមដែលអាចទៅបាន។ ខ្ញុំសង្ឃឹមថាគម្រោងទាំងនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាព ដែលមានរួចមកហើយរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណ!**